# ភ្នាក់ងារ ភីសខ័រ សហរដ្ឋអាមេរិក នៅកម្ពុជា



# របាយការណ៍ប្រចាំឆ្នាំ ២០១៥



អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ក្រុមទី៩ Stephanie Martinez នៅខេត្តបាត់ដំបង

# សារលិខិតពីនាយិកាប្រចាំប្រទេស



ស៊ូសាន ដ្វាយើ
នាយិកាប្រចាំប្រទេស
ភ្នាក់ងារភីសខ័រប្រចាំកម្ពុជា

អតីតអ្នកស្ម័គ្រចិត្តភីសខ័រនៅប្រទេស
យូហ្គោនដា ឆ្នាំ ១៩៩២-១៩៩៤

មិត្តភក្តិ និងដៃគូការងារទាំងអស់ជាទីរាប់អាន!

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំស្តីអំពីសកម្មភាពប្រចាំឆ្នាំ របស់ភ្នាក់ងារ ភីសខ័រ សហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ។ ចាប់ពីឃុំកោះស្តេច ដល់ខេត្តបន្ទាយមានជ័យ មានអ្នកស្ម័គ្រចិត្តច្រើនជាង ៩០នាក់ ដែលកំពុងបំរើការងារជាមួយដៃគូការងារក្នុងស្រុក នៅក្នុងខេត្តចំនួន ១៦ ដើម្បីធ្វើអោយប្រសើរឡើងនូវបេសកកម្មទូទាំងសាកលលោករបស់ភ្នាក់ងារភីសខ័រ ក្នុងការបង្កើតអោយមានមិត្តភាព និងសន្តិភាពនៅលើពិភពលោក។ ដើម្បីធ្វើការងារអោយ ស្រ បទៅតាមអាទិភាពរបស់ក្រសួងសុខា ភិបាលនិងក្រសួងអប់រំយុវជននិងកីឡានៃប្រទេសកម្ពុជាភ្នាក់ងារភីសខ័រប្រចាំនៅកម្ពុជាបានអនុវត្តកម្មវិធីចំនួនពីរគឺ ១) ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស និង ២) ការអប់រំសុខភាពសហគមន៍ ។ តាមរយៈកម្មវិធីទាំងនេះ និងគំរោងបន្ទាប់បន្សំផ្សេងៗទៀត អ្នកស្ម័គ្រចិត្តរបស់យើងបានបំរើប្រជាពលរដ្ឋជាង១០០,០០០នាក់។

ប្រសិនបើយើងក្រឡេកមើលទៅឆ្នាំកន្លងទៅ យើងពិតជាមានអំណរគុណជាខ្លាំងចំពោះដៃគូការងារក្នុងជួររដ្ឋាភិបាល នៃប្រទេសកម្ពុជាចាប់ ពីថ្នាក់ឃុំ ស្រុក ខេត្ត រហូតដល់ថ្នាក់ជាតិ ក្នុងនោះរួមមានក្រសួងអប់រំ យុវជននិងកីឡា ក្រសួង សុខាភិបាល និងក្រសួងមហាផ្ទៃ ដែលបានជួយគាំទ្រ និងសំរួលការងារ ភ្នាក់ងារ ភីសខ័រ អោយដំណើរការទៅបានយ៉ាងល្អ ។ យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះដៃគូការងាររបស់អ្នកស្ម័គ្រចិត្ត ដែលជួយធ្វើអោយការងាររបស់អ្នកស្ម័គ្រចិត្តអាចប្រព្រឹត្តទៅបាន ព្រមទាំងអរគុណគ្រួសារខ្មែរជាម្ចាស់ផ្ទះ ដែលបានយកចិត្តទុកដាក់ថែរក្សាអ្នកស្ម័គ្រចិត្តរបស់យើងបានយ៉ាងល្អ ។ ព្រះរាជាណាចក្រអច្ឆរិយៈ បានក្លាយជាផ្ទះដ៏កក់ក្តៅសំរាប់អ្នកស្ម័គ្រចិត្តរបស់ភ្នាក់ងារ ភីសខ័រ ចំនួនប្រាំបួនជំនាន់ហើយ ។ ដោយសារភាពជាដៃគូដ៏រឹងមាំនេះហើយ យើងរំពឹងថានឹងធ្វើការពង្រីកកម្មវិធីរបស់យើង បន្ថែមទៀតក្នុងឆ្នាំ២០១៦ខាងមុខនេះ។

ខ្ញុំសង្ឃឹមថាអ្នកទាំងអស់គ្នានឹងអានរបាយការណ៍ស្តីពីលទ្ធផលដែលយើងបានសំរេចបានក្នុងឆ្នាំកន្លងទៅនេះដោយក្តីរីករាយ ។ របាយការណ៍នេះមិនត្រឹមតែឆ្លុះបញ្ចាំងអំពីភាពខ្លាំងក្នុងភាពជាដៃគូរបស់យើងប៉ុណ្ណោះទេប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងអំពីក្រុមអ្នកស្ម័គ្រចិត្តដែលមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការចំណាយពេលចំនួន២៧ខែនៃជីវិតរបស់ពួកគេ មករស់នៅ និងបំរើប្រជាជនកម្ពុជា តាមរយៈស្ថាប័នមួយក្នុង ចំណោមស្ថាប័នដែលមានតំលៃបំផុតនៅសហរដ្ឋអាមេរិក ។ ពួកគេមានអាយុចាប់ពី២២ ដល់៦២ឆ្នាំ ហើយតំណាងអោយភាពចំរុះជាតិសាសន៍នៃសហរដ្ឋអាមេរិក ដែលមានពណ៌សម្បុរ កំរិតជីវភាព ជាតិសាសន៍ និងសាសនាផ្សេងៗគ្នា ។ លើសពីនេះទៅទៀត ពួកគេតំណាងអោយតំលៃដ៏ពិតប្រាកដនៃពិភពលោកមួយ ដែលមានពោរពេញទៅដោយសន្តិភាព និងភាពសម្បូរសប្បាយរុងរឿង ។

យើងរំពឹងទុកថាឆ្នាំថ្មីខាងមុខនេះគឺជាឆ្នាំដ៏អស្ចារ្យ។ ប្រសិនបើលោកអ្នក មានសំណួរផ្សេងៗពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬមានមតិយោបល់ដែលអាចជួយបង្កើនផលប៉ះពាល់ល្អនៃការងាររបស់យើង សូមមេត្តាទាក់ទងមកកាន់នាងខ្ញុំ ។



ស៊ូសាន ដ្វាយើ
នាយិកាប្រចាំប្រទេស

# ទិដ្ឋភាពទូទៅ

ភ្នាក់ងារ ភីសខ័រ បញ្ជូនជនជាតិអាមេរិកល្អៗបំផុតប្រកបដោយចំណេះដឹង ដែលជាតំណាងអោយសហរដ្ឋអាមេរិក ទៅក្រៅប្រទេស ដើម្បីជួយដោះស្រាយបញ្ហាដែលជាតំរូវការបន្ទាន់របស់ប្រជាជនទូទាំងពិភពលោក ។ អ្នកស្ម័គ្រចិត្តទាំងអស់ ធ្វើការនៅតាមសហគមន៍ដើម្បីបង្កើតដំណោះស្រាយប្រកបដោយនិរន្តរភាព ដែលឆ្លើយតបនឹង បញ្ហាផ្សេងៗក្នុងវិស័យកសិកម្ម ការ អភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន ។ តាមរយៈការបំរើសេវាកម្មរបស់ពួកគេ អ្នកស្ម័គ្រ ចិត្តទាំងអស់ទទួលបាននូវការយល់ដឹងអំពីវប្បធម៌ ពិសេសមួយនឹងការប្តេជ្ញាចិត្តក្នុងមួយជីវិតរបស់គេក្នុងការបំរើការងារដែល អាចអោយគេស្ថិតក្នុងតួនាទីមួយដែលនាំអោយពួកគេទទួលបានភាពជោគជ័យក្នុងសង្គមបច្ចុប្បន្ននេះ ។

ភ្នាក់ងារនេះបានចាប់ផ្តើមតាំងពីឆ្នាំ១៩៦០មកម្លេះ នៅពេលដែលអតីតសមាជិកព្រឹទ្ធសភាលោក John F. Kennedy បាននាំនិស្សិតនៅសកលវិទ្យាល័យ Michigan អោយបំរើប្រទេសរបស់ពួកគេ ដោយការរស់នៅ និងធ្វើការនៅក្នុងតំបន់ដាច់ស្រយាលមួយចំនួននៃពិភពលោក ។ លោកបានបណ្តុះអោយមានចលនាក្នុងចំណោមយុវជនអាមេរិកាំង ដែលបានជំរុញប្រទេសជាតិទាំងមូល និងបានដឹកនាំរហូតដល់មានការបង្កើតឡើងនូវភ្នាក់ងារ ភីសខ័រ ។ នៅក្នុងពិភពលោកមួយដែលពោរពេញទៅដោយការផ្លាស់ប្តូរ ភ្នាក់ងារនេះ បានក្លាយជាភ្នាក់ងារឆ្នើមដែលប្រកបដោយភាពស្វាហាប់ និងដំណើរឆ្ពោះទៅមុខ ក្នុងវិស័យសេវាកម្មអន្តរជាតិ ដោយសារគំនិតច្នៃប្រឌិតថ្មី និងសេចក្តីអាណិតមេត្តារបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ បេសកកម្មដំបូងរបស់ភ្នាក់ងារនេះគឺនៅតែមិនផ្លាស់ប្តូរះ

**បេសកកម្មរបស់ភ្នាក់ងារ ភីសខ័រ**

ដើម្បីបង្កើនមិត្តភាព និងសន្តិភាពនៅលើពិភពលោក ដោយបំពេញនូវគោលដៅចំនួនបីះ

- ▲ ផ្តល់អ្នកស្ម័គ្រចិត្តទាំងបុរស និងស្ត្រី ដែលបានទទួលការបណ្តុះបណ្តាល ទៅចូលរួមជួយប្រជាជននៅក្នុងបណ្តាប្រទេសដែលចាប់អារម្មណ៍លើភ្នាក់ងារ ភីសខ័រ ។
- ▲ ជួយអ្នកស្ម័គ្រចិត្តអាមេរិកាំងអោយមានការយល់ដឹងកាន់តែប្រសើរអំពីប្រជាជនទាំងឡាយដែលពួកគេធ្វើការជាមួយ ។
- ▲ ជួយបង្កើនការយល់ដឹងរបស់ប្រជាជននៅជុំវិញពិភពលោក អោយបានយល់ដឹងកាន់តែប្រសើរអំពីជនជាតិអាមេរិកាំង ។



លោកប្រធានាធិបតី John F. Kennedy និងនាយកភ្នាក់ងារ ភីសខ័រ លោក Sargent Shriver ស្វាគមន៍អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ទៅកាន់ប្រទេស Tanganyika និង Ghana នៅក្នុងការិយាល័យរបស់លោកប្រធានាធិបតី ។



លោកប្រធានាធិបតី John F. Kennedy ស្វាគមន៍អ្នកស្ម័គ្រចិត្តនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៦១ ។

**ប្រវត្តិ**

| | |
|---|---|
| ត្រូវបានបង្កើតជាផ្លូវការ | ថ្ងៃទី ០១ ខែមីនា ឆ្នាំ១៩៦១ |
| ជនជាតិអាមេរិកាំងដែលបានបំរើការងារ | ២២០,០០០ |
| ប្រទេសសាមីដែលត្រូវបានបំរើមកដល់បច្ចុប្បន្ន | ១៩១ |

**ភ្នាក់ងារភីសខ័រ បច្ចុប្បន្នះ**

| | |
|---|---|
| នាយិកាភ្នាក់ងារភីសខ័រ | Carrie Hessler-Radelet |
| | (អតីតអ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រនៅប្រទេស Western Samoa ឆ្នាំ ១៩៨១ ដល់ ១៩៨៣) |
| ប្រទេសម្ចាស់ផ្ទះ | ៦៣ |
| អ្នកស្ម័គ្រចិត្ត និងសិក្ខាកាម | ៦,៨១៨ |
| យេនឌ័រ | ស្ត្រី ៦៣% និង បុរស ៣៧% |
| ស្ថានភាពគ្រួសារ | នៅលីវ ៩៣% និងរៀបការហើយ ៦% |
| ជនជាតិភាគតិច | ២៨% នៃអ្នកស្ម័គ្រចិត្តទាំងអស់ |
| អាយុជាមធ្យម | ២៨ |
| អ្នកស្ម័គ្រដែលមានអាយុលើសពី៥០ឆ្នាំ | ៧% នៃអ្នកស្ម័គ្រចិត្តទាំងអស់ |




# ភ្នាក់ងារភីសខ័រ ប្រចាំនៅកម្ពុជា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញភ្នាក់ងារភីសខ័រអោយមកបើកដំណើរការកម្មវិធីក្នុងប្រទេសកម្ពុជានៅចុងឆ្នាំ ១៩៩២ ហើយកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរត្រូវបានចុះហត្ថលេខានៅឆ្នាំ ១៩៩៤ ។ ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពនយោបាយមិនមានស្ថេរភាពគ្រប់គ្រាន់សំរាប់អោយអ្នកស្ម័គ្រចិត្តចូលមកកម្ពុជាក្នុងពេលនោះ ។ នៅឆ្នាំ២០០៤ ការពិភាក្សាគ្នាអំពីការបង្កើតអោយមានភ្នាក់ងារភីសខ័រកម្ពុជាបានបន្តទៀត ហើយភ្នាក់ងារ ភីសខ័រ បានស្វាគមន៍អ្នកស្ម័គ្រចិត្តក្រុមទីមួយមកកាន់ប្រទេសកម្ពុជានៅឆ្នាំ២០០៧។

មនុស្សម្នាក់ៗដែលត្រូវបំរើការជាអ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រត្រូវបានជ្រើសរើសតាមរយៈដំណើរការដាក់ពាក្យសុំដែលពោពេញទៅដោយការប្រកួតប្រជែង ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រមានអាយុចាប់ពី២២ដល់៧៥ឆ្នាំ ហើយតំណាងអោយក្រុមជនជាតិ និងសាសន៍ផ្សេងៗគ្នា ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារ អ្ន' កស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រ និង/ឬ ខ្ពស់ជាងនេះ ។ អ្នកស្ម័គ្រចិត្តមកប្រទេសកម្ពុជាដើម្បីប្រើប្រាស់ជំនាញនិងចំណេះដឹងរបស់ពួកគេដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស តាមរយៈសកម្មភាពផ្ទាល់នៅតាមសហគមន៍ ។ បន្ទាប់ពីបានមកដល់ប្រទេសកម្ពុជា អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលជាច្រើនលើផ្នែកភាសា វប្បធម៌ សុខភាព សុវត្ថិភាព និងបច្ចេកទេស ។ ក្នុងកំឡុងពេលនៃការបំពេញសេវាកម្មរបស់ពួកគេ ភ្នាក់ងារភីសខ័រនឹងផ្តល់ឱកាសអោយមានវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តនិងគ្រូបង្រៀនដៃគូរបស់ពួកគេដើម្បីពង្រឹងជំនាញបច្ចេកទេស និងភាសា ។

អ្នកស្ម័គ្រចិត្តរស់នៅជាមួយគ្រួសារខ្មែរ ដែលមានជីវភាពប្រហាក់ប្រហែលនឹងពលរដ្ឋកម្ពុជានៅក្នុងសហគមន៍របស់ពួកគេ ។ ពួកគេធ្វើការងារជាមួយប្រជាជនកម្ពុជា ដើម្បីជួយពួកគេអោយអនុវត្តការងារដែលមានប្រសិទ្ធិភាព ដើម្បីឈានទៅរកអនាគតមួយដ៏ល្អប្រសើរជាងមុន សំរាប់សហគមន៍ក៏ដូចជាប្រទេសកម្ពុជាទាំងមូល ។

អ្នកស្ម័គ្រចិត្តចំនួន ៤៣៣នាក់ បានបំរើការងារនៅក្នុងខេត្តចំនួន១៦ ក្នុងចំណោមខេត្តទាំង២៤ របស់ប្រទេសកម្ពុជាតាំងពីឆ្នាំ២០០៧ ។

**គំរោងក្នុងពេលបច្ចុប្បន្នៈ**

- ▲ ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស
- ▲ ការអប់រំសុខភាពសហគមន៍



ចំនួនអ្នកស្ម័គ្រចិត្តក្នុងឆ្នាំនិមួយៗចាប់តាំងពីឆ្នាំ២០០៧



ភាគរយនៃអ្នកស្ម័គ្រចិត្តក្នុងកម្មវិធីអប់រំភាសាអង់គ្លេស និងអប់រំសុខភាព មកដល់ពេលបច្ចុប្បន្ន

# ការគាំទ្រពីសំណាក់រដ្ឋាភិបាលកម្ពុជា

## ក្រសួងអប់រំ យុវជន និងកីឡា

អត្ថបទដកស្រង់ចេញពីសន្ទរកថារបស់ឯកឧត្តម **អ៊ឹម ភុច** រដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា ក្នុងពិធីសច្ចាប្រនិធានចូលបំរើការងាររបស់អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ក្រុមទី៩ នៅ ប្រទេសកម្ពុជា កាលពីថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ។



នាយិកាភ្នាក់ងារ ភីសខ័រ Carrie Hessler-Radelet ជួបជាមួយឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

"តាងនាមអោយឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា ខ្លួនខ្ញុំផ្ទាល់ ព្រមទាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំបាទ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសហរដ្ឋអាមេរិកដែលបាន បញ្ជូនអ្នកស្ម័គ្រចិត្តថ្មីៗទាំងអស់នេះមកកាន់ភ្នាក់ងារភីសខ័រប្រចាំនៅកម្ពុជា ។" "ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា ព្រមទាំងខ្ញុំបាទ បានដឹងច្បាស់ថាភ្នាក់ងារ ភីសខ័រ បានជួយបណ្តុះបណ្តាលគ្រូបង្រៀនភាសាអង់គ្លេស ក៏ ដូចជាបង្រៀនភាសាអង់គ្លេសនៅតំបន់ដាច់ស្រយាលក្នុងប្រទេស កម្ពុជាអស់រយៈពេលជាង៨ឆ្នាំហើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រឈមផ្សេងៗនៅតែមាន ហើយយើង ត្រូវតែ ស្វែងរកវិធីទាំងឡាយដើម្បីទទួលបានលទ្ធផលដែលល្អប្រសើរជាងមុន ។"

" ដើម្បីទទួលបានលទ្ធផលល្អបំផុត កិច្ចតែការបង្រៀនទាំងឡាយ ត្រូវតែពាក់ព័ន្ធនឹងជីវិតរស់នៅប្រចាំថ្ងៃ ព្រមទាំងទាក់ទងទៅ នឹង សៀវភៅលំហាត់ និងសំនួរផ្សេងៗ ដើម្បីលើកទឹកចិត្តសិស្សានុសិស្សអោយនិយាយ សរសេរ ស្តាប់ ចែករំលែកគំនិតតាមរយៈការពិភាក្សា ការជជែកដេញដោល ។ល។ លើសពីនេះទៅទៀត ការប្រើបច្ចេកវិទ្យាវ័យឆ្លាត ក៏ដូចជាឧបករណ៍បច្ចេកវិទ្យានិងពត៌មានវិទ្យាពិតជាមានសារៈសំខាន់ណាស់ក្នុងការអប់រំសិស្សានុសិស្សជំនាន់ថ្មីនេះ ។"

"ខ្ញុំសូមជូនពរអ្នកទាំងអស់គ្នាអោយមានសុខភាពល្អ ប្រាជ្ញាវាងវៃ ជោគជ័យ និងសំណាងល្អគ្រប់ពេលវេលា ។"

## ក្រសួងសុខាភិបាល

អត្ថបទដកស្រង់ចេញពីសន្ទរកថារបស់ លោកជំទាវ វេជ្ជបណ្ឌិត **ឱ វណ្ណឌីន** អគ្គនាយកបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាលក្នុងពិធីសច្ចាប្រនិធានចូលបំរើការងាររបស់អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ក្រុមទី៩ នៅប្រទេសកម្ពុជា កាលពីថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ។



នាយិកាភ្នាក់ងារភីស ខ័រ Carrie Hessler-Radelet ជួបជាមួយឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល

"ថ្ងៃនេះខ្ញុំមានសេចក្តីរីករាយណាស់ ដែលបានធ្វើជាតំណាងអោយឯក ឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។"

"យើងបា នទ ទួលស្គាល់ថាតំរូវការគឺនៅមានច្រើនណាស់ ហើយមិនមែន គ្រប់ បញ្ហាគឺសុទ្ធតែ អាចដោះស្រាយបានទាំង អស់នោះ ទេប៉ុន្តែភ្នាក់ងារ ភីសខ័រ កំពុងតែធ្វើអោយមានការផ្លាស់ប្តូរយ៉ាងពិតប្រាកដក្នុងជីវិតរបស់ប្រជាជនកម្ពុជាទាំងឡាយដែលពួកគេបានធ្វើការជាមួយ។កម្មវិធីរបស់ភ្នាក់ងារភីសខ័រកំពុងធ្វើការរួមចំណែកដ៏សំខាន់ក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ។"

"ក្នុងនាមក្រសួងសុខាភិបាល ខ្ញុំសូមអំពាវនាវអោយមន្ទីរសុខាភិបាលខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មណ្ឌលសុខភាព បន្តជ្រោមជ្រែង និងសហប្រតិបត្តិការជាមួយភ្នាក់ងារ ភីសខ័រ និងអ្នកស្ម័គ្រចិត្តដែលធ្វើការនៅក្នុងតំបន់របស់លោកអ្នក ។ ខ្ញុំក៏សូមធ្វើសេចក្តីអំពាវនាវនេះផងដែរទៅកាន់ស្ថាប័ន និងអជ្ញាធរពាក់ព័ន្ធទាំងអស់ ។ ខ្ញុំសូមលើកទឹកចិត្តអោយអ្នករាល់គ្នាជួយ រក្សាសុវត្ថិភាពដល់អ្នកស្ម័គ្រចិត្តទាំងអស់ ដើម្បីអោយពួកគេអាចបន្តអនុវត្តការងារដ៏ប្រសើរ ដែលយើងបានស្នើសុំអោយពួក គេជួយធ្វើ ។ សូមគិតថានេះគឺជាឱកាសដ៏ល្អមួយសំរាប់យើងទាំងអស់គ្នា ដែលបានធ្វើការជាមួយភ្នាក់ងារ ភីសខ័ររបស់សហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍប្រទេសរបស់យើង ។" "ជាថ្មីម្តងទៀត ខ្ញុំសូមសំដែងការកោតសសើរចំពោះអ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ដែលនឹងត្រូវព្យាយាមយកឈ្នះនូវរាល់ការលំបាក និង/ឬការប្រឈមផ្សេងៗ ដែលពួកគេអាចនឹងជួបខណៈពេលដែលពួកគេរស់នៅ និងធ្វើការក្នុងប្រទេសកម្ពុជា ។" "ជាចុងបញ្ចប់ ខ្ញុំសូមជូនពរអ្នកទាំងអស់គ្នានូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ ។"



អ្នកស្ម័គ្រចិត្តក្រុមទី៩ ដែលទើបនឹងបានធ្វើសច្ចាប្រនិធានចូលបំរើការងារ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥

# អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្ន

**ស្ថិតិឆ្នាំ ២០១៥**

| | |
|---|---|
| ចំនួនអ្នកស្ម័គ្រចិត្ត | ៩៩នាក់ បំរើការងារនៅក្នុងខេត្តចំនួន ១៦ |
| គំរោង | ៥៦នាក់៖ ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស<br>៤៣នាក់៖ ការអប់រំសុខភាពសហគមន៏ |
| យេនឌ័រ | ៥៩នាក់ជាស្ត្រី<br>៤០នាក់ជាបុរស |
| អាយុ | ៩០% ចាប់ពីអាយុ ២០ ដល់២៩ឆ្នាំ<br>៥% ចាប់ពីអាយុ ៣០ ដល់ ៣៩ឆ្នាំ<br>៥% ចាប់ពីអាយុ ៤០ ដល់ ៦២ឆ្នាំ<br>២១ឆ្នាំ៖ អ្នកស្ម័គ្រចិត្តក្មេងជាងគេបង្អស់<br>៦២ឆ្នាំ៖ អ្នកស្ម័គ្រចិត្តចាស់ជាងគេបង្អស់ |
| រដ្ឋនៃសហរដ្ឋអាមេរិក | អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្នមកពីរដ្ឋចំនួន ៣២ នៃរដ្ឋទាំង៥០របស់សហរដ្ឋអាមេរិក ។ |




ផែនទីដែលបង្ហាញពីខេត្តដែលអ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ
បានបំរើការងារតាំងពីពេលដែលកម្មវិធីបានចាប់ផ្តើមក្នុងឆ្នាំ២០០៧




អ្នកស្ម័គ្រចិត្តភ្នាក់ងារភីស ខ័រ Ann Choi ពន្យល់ស្ត្រីនៅក្នុងសហគមន៍អំពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយ

# ការអប់រំសុខភាពសហគមន៍

នៅឆ្នាំ ២០០៩ ដោយសារមានការស្នើសុំពីក្រសួងសុខាភិបាល ភ្នាក់ងារ ភីសខ័រប្រចាំនៅកម្ពុជា បានពង្រីកសកម្មភាពរបស់ខ្លួនដោយការចាប់ផ្តើមគំរោងអប់រំសុខភាពសហគមន៍ ។ គោលបំណងនៃគំរោងនេះ គឺដើម្បីជួយសហគមន៍ និងប្រជាជនកម្ពុជា ជាពិសេសស្ត្រី និងកុមារ ក្នុងការលើកកំពស់សុខភាព និងសុខមាលភាពទូទៅក៏ដូចជាការបង្កើនសមត្ថភាពរបស់ពួកគេដើម្បីដោះស្រាយ បញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងសុខភាព ។ អ្នកស្ម័គ្រចិត្តធ្វើការជាមួយបុគ្គលិកមណ្ឌលសុខភាព អ្នកស្ម័គ្រចិត្តសុខភាពភូមិ និងសាលារៀនផ្សេងៗ ដើម្បីកសាងសមត្ថភាពរបស់ប្រជាជនក្នុងសហគមន៍អោយចេះឆ្លើយតបនឹងតំរូវការផ្នែកសុខភាពរបស់ពួកគេ ។

**គោលដៅរបស់គំរោងៈ**

- ▲ សុខភាពកុមារ និងម្តាយ
- ▲ អាកប្បកិរិយាដែលនាំអោយមានសុខភាពល្អ

**សកម្មភាពរបស់គំរោងៈ**

- ▲ ធ្វើការអប់រំសុខភាពនៅមណ្ឌលសុខភាពសហគមន៍ និងតាមរយៈការចុះតាមផ្ទះ ។
- ▲ លើកកំពស់ការអនុវត្តអាហារូបត្ថម្ភជាវិជ្ជមាន តាមរយៈសួនបន្លែតាមផ្ទះនិងសហគមន៍ និងការបង្ហាញពីការចំអិននិងអោយអាហារកូន ។
- ▲ លើកកំពស់ការពិនិត្យសុខភាពម្តាយមុននិងក្រោយពេលសំរាល ការចាក់ថ្នាំបង្ការ និងការធ្វើផែនការគ្រួសារនៅទូទាំងសហគមន៍។
- ▲ អប់រំប្រជាជនក្នុងសហគមន៍អំពីបញ្ហាអនាម័យនិងទឹកស្អាត ដូចជាការលាងដៃអោយបានត្រឹមត្រូវ ការទប់ស្កាត់និងការព្យាបាលជំងឺរាគរូស ការបាត់បង់ជាតិទឹក និងការព្យាបាលដែលសមស្រប ក៏ដូចជាការរក្សាទុកទឹកស្អាតផងដែរ។
- ▲ ដឹកនាំប្រជាជនអោយចូលរួមក្នុងសកម្មភាពផ្សេងៗ ដូចជាការធ្វើលំហាត់ប្រាណជាក្រុម ការបង្ហាញពីការចំអិនអាហារដែលនាំអោយមានសុខភាពល្អ ពត៌មានអំពីការប្រឆាំងនឹងការជក់បារី និងយុទ្ធនាការបង្កើនការយល់ដឹងអំពីគ្រឿងស្រវឹង និងថ្នាំញៀន។
- ▲ អប់រំប្រជាជនក្នុងសហគមន៍អំពីសុខភាពបន្តពូជ។

## គោលដៅទី ១៖ សុខភាពកុមារ និងម្តាយ

ប្រជាជនក្នុងសហគមន៍ នឹងបង្កើនការយល់ដឹងនិងជំនាញ ព្រមទាំងមានអាកប្បកិរិយាដែលនាំអោយមានសុខភាពល្អសំរាប់កុមារ និងម្តាយ ដែលពាក់ព័ន្ធនឹងអាហារូបត្ថម្ភ អនាម័យនិងទឹកស្អាត អនាម័យនិងការថែទាំសុខភាពមុនពេលសំរាលកូន ។

| កម្មវត្ថុ | លទ្ធផល |
|---|---|
| អាហារូបត្ថម្ភ | ‣ អ្នកថែទាំសុខភាពចំនួន ៤,៣៩៩នាក់ បានរកឃើញនូវវិធានការមួយ ឬច្រើនជាងនេះ ដែលពួកគេអាចធ្វើបានដើម្បីទប់ស្កាត់បញ្ហាកង្វះអាហារូបត្ថម្ភក្នុងគ្រួសាររបស់ពួកគេ។<br>‣ ស្ត្រីចំនួន២៥៨នាក់ត្រូវបានបណ្តុះបណ្តាលអំពីសុខភាពកុមារនិងអាហារូបត្ថម្ភ។<br>‣ កុមារចំនួន ១,៣២៨នាក់ ចាប់ពីអាយុ ៦ ដល់ ៥៩ខែបានទទួលបណ្តុស្តីពីការលូតលាស់ ព្រមទាំងត្រូវបានថ្លឹងទំងន់យ៉ាងហោចណាស់៣ខែម្តង។<br>‣ ស្ត្រីចំនួន ៤៥៥នាក់អាចធ្វើការបង្ហាញអំពីរបៀបរៀបចំអាហារដែលមានអាហារូបត្ថម្ភ និងសុវត្ថិភាពសំរាប់ការបញ្ឈប់ការបំបៅដោះដល់កុមារ។<br>‣ គ្រួសារចំនួន៣៥នាក់ដែលត្រូវបានបណ្តុះបណ្តាលដោយអ្នកស្ម័គ្រចិត្តបានរាយការណ៍ថាទទួលបានអាហារស្រស់ៗក្នុងរយៈពេល៦ខែបន្ទាប់ពីបានធ្វើសួនបន្លែ។ |
| ការថែទាំសុខភាពមុនពេលសំរាលកូន ការតាមដានសុខភាព និងការសំរាលកូន | ‣ ស្ត្រីចំនួន ៣,១៩០នាក់ ទទួលបានសារអប់រំសុខភាពអំពីសារៈសំខាន់នៃការថែរក្សាសុខភាពមុនពេលសំរាល និងការតាមដានសុខភាពក្រោយពេលសំរាល ការចាក់ថ្នាំបង្ការ ការធ្វើផែនការគ្រួសារ និងសេវាកម្មសំរាលកូន។<br>‣ ស្ត្រីចំនួន ១,៩០១នាក់មានសមត្ថភាពអាចដឹងអំពីសញ្ញានិងអាការៈរោគ ដែលបញ្ជាក់ថាត្រូវការការថែទាំជាបន្ទាន់ក្នុងពេលមានផ្ទៃពោះ។<br>‣ ប្រជាជនក្នុងសហគមន៍ចំនួន ៩៩២នាក់ត្រូវបានអប់រំអំពីវិធីសាស្ត្រពន្យាកំណើតសម័យទំនើប។ |
| ទឹកស្អាត និងអនាម័យ | ‣ ប្រជាជនក្នុងសហគមន៍ចំនួន ៣,៦២៧នាក់ អាចកំណត់បាននូវពេលវេលាសំខាន់ចំនួន៣ ឬច្រើនជាងនេះ ដែលពួកគេត្រូវលាងដៃ។<br>‣ ប្រជាជនក្នុងសហគមន៍ចំនួន ៦៩៦នាក់ត្រូវបានបណ្តុះបណ្តាលអោយបន្សុទ្ធនិងរក្សាទុកទឹកស្អាតរបស់ពួកគេអោយបានត្រឹមត្រូវ។<br>‣ ប្រជាជនក្នុងសហគមន៍ចំនួន ១៨៨នាក់អាចបង្ហាញពីរបៀបធ្វើទឹកអោយស្អាតបានយ៉ាងត្រឹមត្រូវ។ |

## គោលដៅទី ២៖ អាកប្បកិរិយាដែលនាំអោយមានសុខភាពល្អ

ប្រជាជនក្នុងសហគមន៍ នឹងមានបំណិនជីវិតកាន់តែល្អជាងមុន ព្រមទាំងមានអាកប្បកិរិយាផ្សេងៗដែលនាំអោយមានសុខភាពល្អ ។

| កម្មវត្ថុ | លទ្ធផល |
|---|---|
| ជំងឺមិនឆ្លង | ‣ ប្រជាជនចំនួន ៣,៦៥៩នាក់ត្រូវបានអប់រំអំពីជំងឺមិនឆ្លង ។<br>‣ ប្រជាជនចំនួន ២,១៩៣នាក់ត្រូវបានអប់រំអំពីកត្តាគ្រោះថ្នាក់នៃជំងឺមិនឆ្លង ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថ្នាំជក់។<br>‣ ប្រជាជនចំនួន ១,២២៤នាក់ អាចដឹងអំពីវិធីផ្សេងៗដែលពួកគេអាចបញ្ចូលសកម្មភាពដែលបញ្ចេញថាមពលរាងកាយក្នុងទំលាប់ប្រចាំថ្ងៃរបស់ពួកគេ ។<br>‣ ប្រជាជនចំនួន ៩៦៧នាក់ត្រូវបានអប់រំអំពីផលប៉ះពាល់អាក្រក់នៃគ្រឿងស្រវឹងនិងសារធាតុដទៃទៀត ។<br>‣ ប្រជាជនចំនួន ៣០៧នាក់ត្រូវបានអប់រំអំពីរបបអាហារដែលនាំអោយមានសុខភាពល្អ។<br>‣ ការធ្វើលំហាត់ប្រាណ ត្រូវបានរៀបចំដោយអ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ និងដៃគូការងាររបស់ពួកគេចំនួន៩៣ដង។ |



អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីស ខ័រ Glynn Pogue បង្រៀនថ្នាក់ភាសាអង់គ្លេស

# ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស

គំរោងបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសា អង់គ្លេស បាននឹងកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃប្រទេសកម្ពុជាតាំងពីឆ្នាំ២០០៧ ។ គំរោងនេះបានធ្វើការដើម្បីអភិវឌ្ឍជំនាញគិតដោយវិភាគ និងភាសាអង់គ្លេសដល់សិស្សានុសិស្ស គ្រូបង្រៀន និងប្រជាជនក្នុងសហគមន៍ ដើម្បីជួយអោយពួកគេទទួលបានឱកាសសិក្សារៀនសូត្របន្ថែម ឱកាសការងារ ក៏ដូចជាឱកាសផ្ទាល់ខ្លួនផងដែរ ។

អ្នកស្ម័គ្រចិត្តបង្រៀននៅតា ម អនុវិទ្យាល័យ វិទ្យាល័យ និងសាលាគរុកោសល្យ ។ ដូចដែលបានស្នើសុំដោយក្រសួងអប់រំ អ្នកស្ម័គ្រចិត្តបង្រៀនរួមគ្នាជាមួយគ្រូជនជាតិខ្មែរ ។ ការធ្វើបែបនេះ មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់សិស្សានុសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែម ទាំងជួយបង្កើនសមត្ថភាពភាសារបស់គ្រូបង្រៀន ព្រមទាំងបង្កើនជំនាញបច្ចេកទេសគ្រប់គ្រងថ្នាក់រៀនរបស់ពួកគេផងដែរ ។ តាមរយៈការបង្រៀនជាមួយគ្រូជនជាតិខ្មែរ អ្នកស្ម័គ្រចិត្ត អាចចែករំលែកវិធីសាស្ត្រក្នុងការបង្រៀនបែបទំនើប ជួយរៀបចំនិងបង្រៀនមេរៀន បង្កើនជំនាញភាសាអង់គ្លេសសំរាប់ការប្រាស្រ័យទាក់ទង និងណែនាំអោយស្គាល់ពីបច្ចេកទេសផ្សេងៗក្នុងការគ្រប់គ្រងថ្នាក់រៀនអោយមានប្រសិទ្ធភាព។

អ្នកស្ម័គ្រចិត្ត ក៏បង្កើតនិងបង្កើនធនធានសំរាប់ការរៀនសូត្រ និងការបង្រៀនផងដែរ ដែលរួមមានដូចជាការណែនាំនូវបច្ចេកវិទ្យាថ្មីៗ ។

**គោលដៅរបស់គំរោង៖**

- ▲ លើកកំពស់ការបង្រៀន
- ▲ បង្កើនភាពជោគជ័យរបស់សិស្សានុសិស្ស

**សកម្មភាពរបស់គំរោង៖**

- ▲ បង្រៀនរួមគ្នាជាមួយគ្រូដៃគូជាជនជាតិខ្មែរក្នុងថ្នាក់រៀន ។
- ▲ បង្កើតកិច្ចតែងការបង្រៀន និងសំភារៈបង្រៀន ដែលប្រើប្រាស់វិធីសាស្ត្រទំនាក់ទំនងក្នុងការបង្រៀនភាសាអង់គ្លេស ។
- ▲ សំរបសំរួលសកម្មភាពសិស្សានុសិស្ស និងក្លឹបសិក្សា ។
- ▲ បង្កើតបណ្ណាល័យ និងមណ្ឌលធនធានសំរាប់ការសិក្សា ។

## គោលដៅទី ១៖ លើកកំពស់ការបង្រៀន

គ្រូបង្រៀននឹងបង្កើនសមត្ថភាពភាសាអង់គ្លេសរបស់ពួកគេ និងអនុវត្តបច្ចេកទេសបង្រៀនបែបសិស្សមជ្ឈមណ្ឌល ។

| កម្មវត្ថុ | លទ្ធផល |
|---|---|
| លើកកំពស់ជំនាញទំនាក់ទំនងជាភាសាអង់គ្លេសរបស់គ្រូបង្រៀន | ▸ គ្រូបង្រៀនចំនួន ៨៥នាក់បានពង្រឹងវិធីសាស្រ្តក្នុងការបង្រៀនភាសាអង់គ្លេសរបស់ពួកគេ ។<br>▸ គ្រូបង្រៀនចំនួន ៧៣នាក់បានប្រើប្រាស់ភាសាអង់គ្លេសមួយភាគធំក្នុងដំណើរការនៃការបង្រៀនក្នុងថ្នាក់របស់ពួកគេ ។<br>▸ គ្រូបង្រៀនចំនួន ៧២នាក់បានបង្កើនការចូលរួមរបស់ពួកគេក្នុងសកម្មភាពអភិវឌ្ឍសមត្ថភាពការងារគ្រូបង្រៀន ជាភាសាអង់គ្លេស ។ |
| លើកកំពស់ការអនុវត្តការបង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេស | ▸ គ្រូបង្រៀនចំនួន ៧៣នាក់បានបង្កើនការប្រើប្រាស់បច្ចេកទេសក្នុងការបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌលរបស់ពួកគេ ។<br>▸ គ្រូបង្រៀនចំនួន ៦៦នាក់ត្រូវបានណែនាំអោយបានដឹងអំពីរចនាសម្ព័ន្ធ ឬទំលាប់ ដែលនាំអោយមានការគ្រប់គ្រងអន្តរកម្មក្នុងថ្នាក់រៀនដោយមានប្រសិទ្ធិភាពជាងមុន ។<br>▸ គ្រូបង្រៀនចំនួន ៦៥នាក់បានបង្កើនការប្រើប្រាស់ការវាយតម្លៃក្នុងថ្នាក់រៀនរបស់ពួកគេ ដើម្បីតាមដាននិងដឹងពត៌មានអំពីការរីកចំរើនរបស់សិស្ស ។<br>▸ គ្រូបង្រៀនចំនួន ៥០នាក់បានបង្កើនការប្រើប្រាស់ធនធានសំរាប់ការរៀនសូត្រក៏ដូចជាសំភារៈក្នុងថ្នាក់រៀន ដោយការបង្កើត ធ្វើអោយប្រសើរឡើង និង គ្រប់គ្រងចំនុចផ្សេងៗដូចជា កិច្ចតែងការបង្រៀន ផ្ទាំងរូបភាព ឯកសារបន្ថែមសៀវភៅក្នុងបណ្ណាល័យ ឬសំភារៈដទៃទៀត ដែលអាចជួយដល់ការរៀនសូត្រនៅក្នុងថ្នាក់រៀន ។ |
| លើកកំពស់ជំនាញបង្រៀនភាសាអង់គ្លេសរបស់គរុសិស្ស | ▸ គរុសិស្សចំនួន ៩០២នាក់បានបង្កើនសមត្ថភាពជំនាញភាសាអង់គ្លេសរបស់ពួកគេយ៉ាងហោចណាស់ ១០% ដូចដែលបានវាស់វែងដោយការវាយតំលៃផ្លូវការ ។<br>▸ គរុសិស្សចំនួន ៥៨៧នាក់បានបង្កើត ធ្វើអោយប្រសើរឡើង ឬគ្រប់គ្រងចំនុចផ្សេងៗដូចជាផ្ទាំងរូបភាព កិច្ចតែងការបង្រៀន ឯកសារបន្ថែម សៀវភៅក្នុងបណ្ណាល័យ ឬសំភារៈដទៃទៀត ដែលអាចជួយដល់ការរៀនសូត្រនៅក្នុងថ្នាក់រៀន ។<br>▸ គរុសិស្សចំនួន ៣៧៦នាក់ បានបង្កើនការប្រើប្រាស់បច្ចេកទេសក្នុងការបង្រៀនបែបសិស្សមជ្ឈមណ្ឌល ។<br>▸ គរុសិស្សចំនួន ៣៣២នាក់បានបង្កើនការប្រើប្រាស់ការអនុវត្តសមធម៌យេនឌ័រក្នុងថ្នាក់រៀន ។ |



អ្នកស្ម័គ្រចិត្ត Miranda Axworthy បង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យមួយក្នុងខេត្តបាត់ដំបង

# សមិទ្ធផល

## គោលដៅទី ២៖ បង្កើនភាពជោគជ័យរបស់សិស្សានុសិស្ស

សិស្សានុសិស្ស ឬយុវជន នឹងបង្កើនសមត្ថភាពភាសាអង់គ្លេស និងអភិវឌ្ឍជំនាញលើភាពជាអ្នកដឹកនាំក្នុងថ្នាក់រៀនភាសាអង់គ្លេស (ផ្លូវការនិងមិនផ្លូវការ) ឬក្នុងសកម្មភាពក្រៅម៉ោងសិក្សា ។

| កម្មវត្ថុ | លទ្ធផល |
|---|---|
| លើកកំពស់ការសំរេចបាន និងការចូលរួមក្នុងថ្នាក់រៀនភាសាអង់គ្លេស | • សិស្សចំនួន ៤,២៦២នាក់បានបង្ហាញការកើនឡើងនៃសមត្ថភាពភាសាអង់គ្លេសរបស់ពួកគេតាមរយៈការវាយតំលៃផ្លូវការ និងមិនផ្លូវការ ដោយផ្អែកលើមេរៀនដែលពួកគេរៀននៅក្នុងថ្នាក់ ។<br>• សិស្សចំនួន ៤,៥៥៩នាក់បានបង្ហាញពីការកើនឡើងនៃការមានទំនុកចិត្ត ឬការមានកំលាំងចិត្ត តាមរយៈការចូលរួមក្នុងថ្នាក់រៀន ក្លឹបសិក្សា ឬការបោះជំរុំ។ |
| លើកកំពស់ជំនាញលើភាពជាអ្នកដឹកនាំ | • សិស្សចំនួន ១,៦០៦នាក់បានបង្ហាញភាពជាអ្នកដឹកនាំនៅក្នុងឬក្រៅថ្នាក់រៀនរបស់ពួកគេ តាមរយៈសកម្មភាពដូចជា មិត្តអប់រំមិត្ត ការជួយបង្រៀន ឬការជួយធ្វើកិច្ចការផ្ទះ ។ |
| ពង្រីកការប្រើប្រាស់បណ្ណាល័យ និង/ឬការប្រើប្រាស់ និងធនធានបច្ចេកវិទ្យាទំនាក់ទំនង និងពត៌មានវិទ្យា (ICT) | • សិស្សចំនួន ២១៦នាក់ទទួលបានឱកាសក្នុងការអានឯកសារកាន់តែច្រើន ឬអាចមានសមត្ថភាពប្រសើរជាងមុន ក្នុងការប្រើប្រាស់ និងចូលទៅប្រើប្រាស់ធនធានអេឡិចត្រូនិច ដោយសារការបង្កើត ឬពង្រីកបណ្ណាល័យរបស់សា លារៀន ឬមជ្ឈមណ្ឌលកំព្យូទ័រ ។ |


ថ្នាក់រៀនទូទៅនៅក្នុងតំបន់ដាច់ស្រយាល ដែលត្រូវបានបង្រៀនដោយអ្នកស្ម័គ្រចិត្តភ្នាក់ងារភីស ខ័រក្នុងគំរោងបណ្តុះបណ្តាលគ្រូបង្រៀន



ក្មេងស្រីនៅក្នុងសហគមន៍មានការត្រេតអរយ៉ាងខ្លាំងដែលបានចូលការបោះជំរុំនៃការលើកម្ពស់ស្ត្រី និងក្មេងស្រីបានចូលសិក្សា

# គំនិតផ្តួចផ្តើម ផ្តល់ឱកាសអោយស្ត្រី និងក្មេងស្រីបានចូលសិក្សា ( Let Girls Learn )

កម្មវិធីផ្តល់ឱកាសអោយស្ត្រីនិងក្មេងស្រីបានចូលសិក្សារបស់ភ្នាក់ងារ ភីសខ័រ មានគោលបំណងពង្រីកឱកាសក្នុងការសិក្សារបស់ក្មេងស្រីនៅទូទាំងពិភពលោកក្នុងសហគមន៍ដែលយើងបំរើការងារ ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រដែលរស់នៅ និងធ្វើការនៅតាមសហគមន៍ នឹងធ្វើការដើម្បីផ្តល់អំណាចដល់អ្នកដឹកនាំក្នុងស្រុក និងជួយបង្កើតដំណោះស្រាយប្រកបដោយនិរន្តរភាព សំរាប់បញ្ហាអប់រំរបស់ស្ត្រីនិងក្មេងស្រី ។

នៅឆ្នាំ២០១៥ កម្មវិធីផ្តល់ឱកាសអោយស្ត្រីនិងក្មេងស្រីបានចូលសិក្សា បានផ្តល់ថវិកាប្រមាណ ១៧,០០០ដុល្លាអាមេរិក ដល់គំរោងចំនួន ៧ ។

| | |
|---|---|
| ប្រជាជនក្នុងសហគមន៍ចំនួន ១,៥៨៣នាក់ (៥១% ជាស្ត្រីនិងក្មេងស្រី) | បានចូលរួមដោយផ្ទាល់ក្នុងការបង្កើតនិងអនុវត្តគំរោង ដោយរួមទាំងអ្នកដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ។ |
| ប្រជាជនក្នុងសហគមន៍ចំនួន ៤,២៩៨នាក់ (៥៣% ជាស្ត្រីនិងក្មេងស្រី) | បានទទួលផលប្រយោជន៍ដោយប្រយោលពីគំរោងទាំងអស់ ។ |
| ប្រជាជនក្នុងសហគមន៍ចំនួន ៣,៩៨០នាក់ និងអ្នកផ្តល់សេវាកម្មចំនួន ៨៨នាក់ | បានបង្កើនសមត្ថភាពបច្ចេកទេសរបស់ខ្លួនដោយសារគំនិតផ្តួចផ្តើម ផ្តល់ឱកាសអោយស្ត្រី និងក្មេងស្រីបានចូលសិក្សា ។ |
| ប្រជាជនចំនួន ២,៧២៦នាក់ | បានប្រើប្រាស់បច្ចេកវិទ្យា និង/ឬ ការអនុវត្តថ្មីៗ ដែលជាលទ្ធផលនៃគំនិតផ្តួចផ្តើម ផ្តល់ឱកាសអោយស្ត្រី និងក្មេងស្រីបានចូលសិក្សា ។ |



សិស្សានុសិស្សសិក្សាអំពីសារសំខាន់នៃការលាងដៃ

# កម្មវិធីភាពជាដៃគូរបស់ភ្នាក់ងារ ភីសខ័រ

កម្មវិធីភាពជាដៃគូរបស់ភ្នាក់ងារ ភីសខ័រ (PCPP) ធ្វើការផ្សារភ្ជាប់ក្រុមឬបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍លើកម្មវិធី ហើយអនុញ្ញាតអោយពួកគេធ្វើការបរិច្ចាកដោយផ្ទាល់ដល់គំរោង ដែលឆ្លើយតបនឹងតំរូវការបន្ទាន់ក្នុងការអភិវឌ្ឍសហគមន៍ ដែលអ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ បំរើការងារ ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ និងដៃគូការងារជាជនខ្មែររបស់ពួកគេ បង្កើតគំរោងជាមួយគ្នា ហើយស្វែងរកថវិកាតាមរយៈកម្មវិធីភាពជាដៃគូរបស់ភ្នាក់ងារ ភីសខ័រ ។ គំរោងដែលត្រូវបានអនុវត្តនៅឆ្នាំ២០១៥ បានជួយក្នុងវិស័យមួយចំនួនដូចជា ការអប់រំ សុខភាព ការអភិវឌ្ឍការងារ និងការអភិវឌ្ឍយុវជន ។

នៅឆ្នាំ២០១៥ កម្មវិធីភាពជាដៃគូរបស់ភ្នាក់ងារ ភីសខ័រ បានផ្តល់ជំនួយប្រមាណ ៣៤,០០០ដុល្លាអមេរិក ដល់គំរោងចំនួន១៦ ។

| | |
|---|---|
| ប្រជាជនក្នុងសហគមន៍ ចំនួន ២,៦៣២នាក់ | បានចូលរួមដោយផ្ទាល់ក្នុងការបង្កើតនិងអនុវត្តគំរោង ដោយរួមទាំងអ្នកដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ។ |
| ប្រជាជនក្នុងសហគមន៍ ចំនួន ៥,៦១៩នាក់ | បានទទួលផលប្រយោជន៍ដោយប្រយោលពីគំរោងទាំងអស់ ។ |
| ប្រជាជនក្នុងសហគមន៍ ចំនួន ៤,៥២១នាក់ និង អ្នកផ្តល់សេវាកម្មចំនួន ៣២០នាក់ | បានបង្កើនសមត្ថភាពបច្ចេកទេសរបស់ខ្លួនដោយសារគំរោងផ្សេងៗរបស់កម្មវិធីភាពជាដៃគូរបស់ភ្នាក់ងារ ភីសខ័រ ។ |
| ប្រជាជនចំនួន ៣,៧០០នាក់ | បានប្រើប្រាស់បច្ចេកវិទ្យា និង/ឬ ការអនុវត្តថ្មីៗ ដែលជាលទ្ធផលនៃគំរោងផ្សេងៗរបស់កម្មវិធីភាពជាដៃគូរបស់ភ្នាក់ងារ ភីសខ័រ ។ |

# ជំនួយសំរាប់គំរោងតូចៗ

កម្មវិធីជំនួយសំរាប់គំរោងតូចៗ (SPA) គឺជាកិច្ចប្រតិបត្តិការរវាងភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងភ្នាក់ងារ ភីសខ័រ ។ គោលដៅនៅក្នុងប្រទេសកម្ពុជា គឺដើម្បីគាំទ្រគំរោងអភិវឌ្ឍសហគមន៍ផ្សេងៗលើវិស័យដូចជាសុខភាព កសិកម្ម និងការអប់រំជាមូលដ្ឋាន ។

ដោយមានកិច្ចសហប្រតិបត្តិការជាមួយដៃគូការងារជាជនជាតិខ្មែររបស់ពួកគេ អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រកម្ពុជា ជួយសហគមន៍ទាំងឡាយអោយសំរេចបាននូវគោលដៅអភិវឌ្ឍន៍ ដែលពាក់ព័ន្ធនឹងការកសាងសមត្ថភាព និងនិរន្តរភាព ។ គំរោងទាំងឡាយមានរួមបញ្ចូលប្រធានបទក្នុងវិស័យផ្សេងៗដូចជា៖ សុខភាព បំណិនជីវិត ការអប់រំ ការបង្កើតប្រាក់ចំណូល អាជីវកម្ម សិល្បៈ និងភាពជាអ្នកដឹកនាំ ។

នៅឆ្នាំ ២០១៥ កម្មវិធីជំនួយសំរាប់គំរោងតូចៗ បានផ្តល់ជំនួយប្រមាណ ៩០,០០០ដុល្លាអាមេរិក ដល់គំរោងចំនួន២៣ ។

| | |
|---|---|
| ប្រជាជនក្នុងសហគមន៍ ចំនួន ២,៥៨០នាក់ | បានចូលរួមដោយផ្ទាល់ក្នុងការបង្កើតនិងអនុវត្តគំរោង ដោយរួមទាំងអ្នកដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ។ |
| ប្រជាជនក្នុងសហគមន៍ ចំនួន ១៤,៧០១នាក់ | បានទទួលផលប្រយោជន៍ដោយប្រយោលពីគំរោងទាំងអស់ ។ |
| ប្រជាជនក្នុងសហគមន៍ ចំនួន ៦,៥២៩នាក់ និងអ្នកផ្តល់សេវាកម្មចំនួន ២៤៧នាក់ | បានបង្កើនសមត្ថភាពបច្ចេកទេសរបស់ខ្លួនដោយសារជំនួយថវិការបស់កម្មវិធីជំនួយសំរាប់គំរោងតូចៗ ។ |
| ប្រជាជនចំនួន ៣,៩២៧នាក់ | បានប្រើប្រាស់បច្ចេកវិទ្យា និង/ឬ ការអនុវត្តថ្មីៗ ដែលជាលទ្ធផលនៃជំនួយថវិការបស់កម្មវិធីជំនួយសំរាប់គំរោងតូចៗ ។ |




កុមារនៅក្នុងសហគមន៍បង្ហាញលទ្ធផលនៃការគូររូបរបស់ពួកគេពីក្លឹបគំនូរ ដែលត្រូវបានបង្កើតឡើងដោយអ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ



សិស្សានុសិស្សរៀនអំពីតន្ត្រីបុរាណខ្មែរ

# គំនិតផ្ដួចផ្ដើមចំរុះ

អ្នកស្ម័គ្រចិត្ត ដាក់បញ្ចូលគំរោងចំរុះរបស់ភ្នាក់ងារ ភីសខ័រ ទៅក្នុងការងាររបស់ពួកគេ ដោយការធ្វើសកម្មភាពទាក់ទងនឹងការអភិវឌ្ឍយុវជន ការបង្កើនការយល់ដឹងអំពីយែនឌ័រ នឹងស្មារតីនៃការស្ម័គ្រចិត្ត ។ នៅឆ្នាំ២០១៤ អ្នកស្ម័គ្រចិត្តបានចូលទៅដល់ប្រជាជនជាង ១៩,៦៩០នាក់ តាមរយៈសកម្មភាពចំនួន៩៨៥ ដែលរួមមានដូចជា ក្លឹប ការបោះជំរុំ សិក្ខាសាលា និងកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀត ។



### យុវជនជាធនធាន

សកម្មភាពចំនួន ១១៣ ត្រូវបានធ្វើឡើងបាននាំអោយយុវជនចូលរួមចំណែកក្នុងគំរោងផ្សេងៗដូចជា៖ ការធ្វើអោយមានភាពប្រសើរឡើងក្នុងសហគមន៍ ការលើកកំពស់សុខភាពបរិស្ថាន និងគំរោងផ្សេងៗដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ។



### សន្តិសុខស្បៀង

សកម្មភាពសន្តិសុខស្បៀងចំនួន៧៧ ត្រូវបានធ្វើឡើងដើម្បីផ្ដោតទៅលើភាពក្រីក្រដែលរួមមានភាពខ្វះជីវជាតិនិងកង្វះអាហារូបត្ថម្ភតាមរយៈការបង្កើតអោយមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ។

### សមភាពយែនឌ័រ និងការផ្ដល់អំណាចដល់ស្ត្រី

សកម្មភាពចំនួន៨៣ បានបញ្ចូលការពិចារណាលើយែនឌ័រ បានលើកកំពស់សមភាពយែនឌ័រនិងការផ្ដល់អំណាចដល់ស្ត្រី និងបានចូលទៅដល់ក្រុមស្ត្រី ក្មេងស្រី ក្មេងប្រុស និងបុរសដែលពីមុនមកមិនត្រូវបានទទួលនូវឱកាស ផលប្រយោជន៍ និងជំនាញផ្សេងៗ ។



### ស្មារតីក្នុងការស្ម័គ្រចិត្ត

សកម្មភាពចំនួន៦៨ ត្រូវបានធ្វើឡើងបាននាំអោយយុវជនចូលរួមក្នុងការធ្វើអោយមានភាពប្រសើរឡើងក្នុងសហគមន៍ ការលើកកំពស់សុខភាពបរិស្ថាន និងគំរោងផ្សេងៗដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ។



## អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ Giselle Campos

មានកត្តាជាច្រើនដែលធ្វើអោយការបំពេញសេវាកម្មភ្នាក់ងារ ភីសខ័រ របស់ខ្ញុំនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈពិសេស ។ ប៉ុន្តែ អ្វីដែលខ្ញុំចង់និយាយជាងគេនោះគឺបទពិសោធន៍រស់នៅជាមួយគ្រួសារខ្មែររបស់ខ្ញុំ ។ តាំងពីថ្ងៃទីមួយ គ្រួសារខ្មែររបស់ខ្ញុំបានជួយខ្ញុំដោយអស់ពីចិត្ត ហើយតែងតែនៅជាមួយខ្ញុំនៅពេលដែលខ្ញុំត្រូវការការណែនាំពីពួកគាត់ ។ ពួកគាត់មិនដែលរារែកក្នុងការជួយខ្ញុំម្តងណាឡើយ តាំង ពីការដើរផ្សាររហូតដល់ការគូរផែនទីសំរាប់អោយខ្ញុំជិះកង់ ។ អ្វីដែលសំខាន់ជាងគេនោះគឺពួកគាត់មានការអត់ធ្មត់ចំពោះខ្ញុំ នៅពេលដែលខ្ញុំពិបាកនិយាយភាសាខ្មែរ ហើយពួកគាត់ក៏មិនដែលសំដែងការធុញទ្រាន់នឹងសំនួរជាច្រើនអនេកដែលខ្ញុំបានសួរទៅកាន់ពួកគាត់អំពីវប្បធម៌ខ្មែរដែរ ។ ពួកគាត់ចូលចិត្តនិយាយថាខ្ញុំធ្វើខ្លួនដូចជាកូនស្រីខ្មែរដ៏ល្អម្នាក់ ពីព្រោះពួកគាត់ឃើញខ្ញុំលាងចានរាល់ពេលដែលយើងញ៉ាំបាយជុំគ្នាហើយ ។ ទង្វើបន្តិចបន្តួច ពិតជាអាចជួយអោយទទួលបានលទ្ធផលល្អមែន ។

លើសពីនេះ ខ្ញុំក៏មានអំណរគុណខ្លាំងណាស់ដែរ ដែលសហគមន៍របស់ខ្ញុំបានទទួលយកខ្ញុំដោយភាពកក់ក្តៅ ។ ខ្ញុំប្រហែលជាមិនអាចសំរេចបានដូចនេះទេប្រសិន បើគ្រួសារខ្មែររបស់ខ្ញុំមិនបានពន្យល់ដល់អ្នកនៅក្នុងសហគមន៍អំពីមូលហេតុដែលខ្ញុំមកទីនេះ ។ ទោះបីជាសកម្មភាពរបស់ពួកគាត់មើលទៅមិនសូវជាធំដុំក៏ដោយ ក៏ប៉ុន្តែពួកគាត់បានជួយអោយដំណើរការនៃការចូលខ្លួនរស់នៅក្នុងសហគមន៍របស់ខ្ញុំមានភាពងាយស្រួល ។ សហគមន៍របស់ខ្ញុំបានទទួលស្វាគមន៍ខ្ញុំដោយបើកចិត្តរបស់ពួកគេយ៉ាងទូលាយ តាំងពីការគិតថ្លៃខ្ញុំជាជនជាតិបរទេសរហូតដល់គិតថ្លៃដូចជនជាតិខ្មែរ ហើយរហូតមកដល់ពេលនេះជួនកាលនៅក្នុងផ្សារពួកគាត់ក៏អោយរបស់របរមកខ្ញុំដោយឥតគិតថ្លៃផងដែរ ។ ខ្ញុំពិតជាអរគុណដល់គ្រួសារខ្មែររបស់ខ្ញុំណាស់ ។ ខ្ញុំស្រឡាញ់ពួកគាត់ដូចជាគ្រួសារផ្ទាល់ខ្លួនរបស់ខ្ញុំដែរ ហើយខ្ញុំនឹងស្រឡាញ់និងថែរក្សាអោយបានល្អបំផុតក្នុងមួយជីវិតរបស់ខ្ញុំ ។



Giselle និងគ្រួសារខ្មែររបស់នាងនៅវត្ត

## អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ Laura Harris



Laura និងម្តាយខ្មែររបស់នាង

ខ្ញុំរស់នៅលើកោះមួយជាមួយម្តាយខ្មែររបស់ខ្ញុំ ។ យើងបានទៅចូលរួមពិធីរៀបអាពាហ៍ពិពាហ៍របស់គេជាច្រើន យើងបានមើលផ្កាយ សួរសំនួរអំពីសង្គ្រាម ជជែកគ្នាលេងអំពីគោលបំណងនៃជីវិតមនុស្ស និងសត្វសមុទ្រ យើងបានបោកខោអាវ ញ៉ាំអាហារ ចំអិនអាហារ និង យំជាមួយគ្នា ។ ខ្ញុំកំពុងរៀនចំអិនម្ហូបខ្មែរ ហើយគាត់ក៏កំពុងរៀនចំអិនម្ហូបអាមេរិកផងដែរ ។ គាត់ចាត់ទុកខ្ញុំដូចជាកូនស្រីរបស់គាត់ដែរ ។ ខ្ញុំតែងតែគិតថាខ្ញុំនឹងត្រូវរៀនភាសាថ្មីមួយ ហើយជួយបង្រៀនភាសាអង់គ្លេស និង មានមិត្តភក្តិថ្មីៗ ។ ខ្ញុំមិនដែលបានដឹងសោះថាខ្ញុំនឹងមានម្តាយទីពីរនោះទេ ។

មូលហេតុមួយផ្នែកដែលធ្វើអោយខ្ញុំមានទំនាក់ទំនងដ៏ល្អជាមួយនឹងម្តាយខ្មែររបស់ខ្ញុំគឺខ្ញុំជួយគាត់ធ្វើការងារផ្ទះ ។ អ្នកស្ម័គ្រចិត្តបានបន្ថែមបន្ទុកលើស្ត្រីដែលនៅក្នុងផ្ទះដូចជាត្រូវបង្រៀន "កូនក្មេង" អាមេរិកម្នាក់អោយចេះញ៉ាំចំណីអាហារ មើលថែខ្លួនឯង និង បោកខោអាវ ដោយខ្លួនឯង ។ ខ្ញុំចូលចិត្តជួយគាត់ ។ ខ្ញុំចង់រៀនអំពីជីវិតរបស់ប្រជាជនខ្មែរអោយបានច្រើនបំផុតតាមដែលខ្ញុំអាចធ្វើបាន ហើយក៏ចង់ចូលខ្លួនអោយស្របតាមវប្បធម៌ខ្មែរអោយបានច្រើនបំផុតដែរ ។ ខ្ញុំពិតជាមានអំណរគុណជាខ្លាំងដែលខ្ញុំអាចមានឱកាសក្នុងការរៀនធ្វើរឿងផ្សេងៗតាមរបៀបរបបនៃជនជាតិខ្មែរ ។

ខ្ញុំនិងម្តាយខ្ញុំមានការយល់ពីគ្នា តាមរយៈការប្រាស្រ័យទាក់ទងគ្នានិងការគិតរបស់យើង ហើយវាគឺជារឿងមួយដ៏អស្ចារ្យ ។ ខ្ញុំបានរៀនសូត្រយ៉ាងច្រើនពីគាត់ដូចជា រៀនក្រោកឈរដោយម៉ឺងម៉ាត់ដើម្បីខ្លួនឯងប៉ុន្តែក្នុងលក្ខណៈទន់ភ្លន់ ចិត្តល្អ និងអធ្យាស្រ័យខ្ពស់ រៀនអំពីគំនិតរបស់គាត់ពាក់ព័ន្ធនឹងទំនាក់ទំនងយែនឌ័រ នឹងការចិញ្ចឹមកូន ។ ខ្ញុំនឹង ចងចាំ និង ថែរក្សាមេរៀន និងរឿងទាំងអស់ដែលខ្ញុំបានរៀនពីគាត់ ហើយអ្វីទាំងអស់នោះនឹងប៉ះពាល់ជាវិជ្ជមានដល់របៀបដែលខ្ញុំចិញ្ចឹមកូននិងរស់នៅក្នុងសង្គម ។ ខ្ញុំពិតជាមានការលំបាកក្នុងការសរសេរអត្ថបទនេះណាស់ ពីព្រោះខ្ញុំមិនចង់គិតដល់ថ្ងៃដែលខ្ញុំត្រូវចាកចេញពីកោះដ៏តូចនិងស្រស់ស្អាត ហើយគួរអោយស្រលាញ់ និង ពោរពេញទៅដោយមនុស្សចំរុះដ៏គួរអោយចាប់អារម្មណ៍ ព្រមទាំងផ្ទះចំរុះពណ៌នៅពីលើសមុទ្រ សត្វត្រីនិងផ្កាថ្មនោះទេ ។

## គំរោងប្រព័ន្ធទឹកស្អាតនិងអណ្តូងក្នុងសាលាបឋមសិក្សា

ដោយអ្នកស្ម័គ្រចិត្ត៖ ***Evalynn Romano***



សិស្សសាលបឋមសិក្សារីករាយដែលមានប្រពន្ធ័ទឹកស្អាតសម្រាប់លាងដៃ

សាលាបឋមសិក្សាកោះ រាម ស្ថិតនៅក្នុងភូមិដាច់ស្រយាលមួយនៃព្រះរាជាណាចក្រកម្ពុជា ។ សាលានេះត្រូវបានដឹកនាំដោយគ្រូមួយក្រុមដែលយកចិត្តទុកដាក់ចំពោះសុខភាពសិស្សរប័ស់ពួកគាត់ ។ ពីមុនម៉ក ប្រភ័ពទឹកដែលអាចប្រើប្រាស់បានសំរាប់តំរូវការអនាម័យជាមូលដ្ឋាន មិនមាននៅក្នុងបរិវេណសាលារៀនទេ ។ អ៊ិន សុខា បានធ្វើជាគ្រូ បង្រៀនម្នាក់នៅក្នុងសាលារៀនបឋមសិក្សាកោះរាមនេះអស់រយៈពេលជាង័ប្រាំបីឆ្នាំហើយ ។ ទោះបីជាគាត់មិនមែនជានាយិកាសាលារៀននេះក៏ដោយ ក៏គាត់គឺជាអ្នកដឹកនាំមួយដែរនៅក្នុងសហគមន៍សាលារៀននេះ តា មរយៈសកម្មភាពមួយចំនួន ។ ការប្តេជ្ញាការប្តេជ្ញារបស់គាត់ ចំពោះការងារ សុខភាពសិស្សានុសិស្សបានបង្ហាញយ៉ាងច្បាស់តាមរយៈការចូលរួមក្នុងសិក្ខាសាលាមួយចំនួនដែលពាក់ព័ន្ធនឹងការអប់រំសុខភាពសិស្សបឋមសិក្សា ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រភពទឹកស្អាតមិនអាចរកបាននៅក្នុងសាលាដើម្បីអោយគាត់អនុវត្តការអប់រំសុខភាពដែលគាត់បានរៀននោះទេ ។ មានថ្ងៃមួយ គាត់មិនអាចអត់ទ្រាំបាននឹងទឹកត្រពាំងដែលមានសារធាតុកខ្វក់នៅក្រោយសាលារៀន ដែលធ្វើអោយសិស្សទាំងឡាយកើតរោគសើស្បែក ព្រមទាំងកង្វះខាតទឹកភ្លៀងសំរាប់ប្រើប្រាស់នៅក្នុងភាពភូមិរបស់គាត់ ។

គោលដៅរបស់គំរោងទឹកស្អាតនេះ គឺដើម្បីអនុវត្តយុទ្ធសាស្ត្រសំរាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។ ដើម្បីសំរេចបាននូវគោលដៅនោះ អណ្តូងមួយត្រូវបានជីក ហើយកន្លែងលាងដៃមួយត្រូវបានធ្វើឡើង ។ ស៊ីទែនផ្ទុកទឹកចំណុះ ២,០០០លីត្រ ចំនួនពីរ និងធុងចំរោះទឹកចំនួនប្រាំបួន(សំរាប់ដាក់ក្នុងថ្នាក់រៀននីមួយៗ)ត្រូវបានទិញយកមកប្រើប្រាស់។លើសពីការមើលឃើញជារូបវន្តទាំងនេះសិស្សានុសិស្សជាង២០០នាក់ អាចថេះមានទំលាប់ និងអនុវត្តបច្ចេកទេសក្នុងលាងដៃបានយ៉ាងត្រឹមត្រូវ ។ គំរោងទឹកស្អាតនេះបានផ្តល់ក្តីសង្ឃឹមដល់សាលារៀន និងសហគមន៍ទាំងមូល ។ ប្រជាជនក្នុងសហគមន៍បានមកជួយគ្នាសាងសង់ប្រព័ន្ធទឹកស្អាតនេះហើយបានជួយធ្វើការងារនេះដោយយកកំរៃសេវាកម្មទាប ដើម្បីជួយសាលាបឋមសិក្សា ពីព្រោះកូនៗរបស់ពួកគេក៏រៀននៅក្នុងសាលារៀននេះដែរ ។ លោកគ្រូអ្នកគ្រូដែលមានបទពិសោធន៍ចូលរួមក្នុងសិក្ខាសាលាស្តីពីការលាងដៃបានអនុវត្តចំណេះដឹងរបស់ពួកគាត់ជាលើកទីមួយនៅក្នុងសាលារៀន ។ សិស្សទាំងឡាយមានសេចក្តីរំភើបចង់រៀនអំពីការលាងដៃ ដោយសារវិធីសាស្ត្រដែលពោរពេញទៅដោយការសប្បាយជុំគ្នាជាមួយសិស្សដទៃ ដែលត្រូវបានដឹកនាំដោយលោកគ្រូអ្នកគ្រូ ។

## សួនបន្លែគ្រួសារផ្តល់អាហាររូបត្ថម្ភ

ដោយអ្នកស្ម័គ្រចិត្ត៖ ***Josephine Mahlie***

ភូមិជាច្រើននៅក្នុងឃុំត្នោតជុំ ខេត្តកំពង់ធំ ស្ថិតនៅចំងាយពី៥ទៅ១១គីឡូម៉ែត្រពីទីប្រជុំជន ដែលបណ្តាលអោយពួកគេមិនមានផ្សារធំមួយដែលពួកគេអាចរករបស់របរ និងបន្លែបង្ការផ្សេងៗបាន ។ ដោយសារកង្វះខាតបន្លែនិងផ្លែឈើទាំងនេះហើយ ដែលធ្វើអោយគ្រួសារជាច្រើនបានធ្វើការសំរេចចិត្តលើចំណីអាហាររបស់ពួកគេមិនបានត្រឹមត្រូវហើយបានចំណាយប្រាក់កាសរបស់ពួកគេលើម្ហូបវេចខ្ចប់ស្រាប់ដែលមានអាហាររូបត្ថម្ភតិចតួច ។ ជាលទ្ធផល បញ្ហាកង្វះអាហាររូបត្ថម្ភបានរី ករាលដាលពាសពេញឃុំ ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ Josie Mahlie បានប្រើប្រាស់ថវិការបស់កម្មវិធីជំនួយសំរាប់ គំរោងតូចៗ (SPA) ដើម្បី ដោះស្រាយបញ្ហា ប្រឈមនេះ ដោយរៀបចំវគ្គ បណ្តុះបណ្តាលស្តីពីការធ្វើសួនបន្លែក្នុងភូមិផ្សេងៗទូទាំ ង ឃុំ ដើម្បី ផ្តោតលើគ្រួសារដែលមា នកូន និង សមាជិកគ្រួសារដែលមានបញ្ហា កង្វះទំងន់ ។



ស្រីក្នុងសហគមន៍សិក្សាអំពី សួនបន្លែគ្រួសារផ្តល់អាហារូបត្ថម្ភ

ចំនួនគ្រួសារ បានកើនឡើងរហូតដល់លើស៥០%នៃចំនួនគ្រួសារគោលដៅដែលដំបូងមានចំនួនត្រឹមតែដប់ ។ ពត៌មានអំពីវគ្គបណ្តុះបណ្តាលធ្វើសួនបន្លែបានលេចលឺដល់គ្រួសារជាច្រើន ហើយគ្រួសារច្រើនជាងការរំពឹងទុក បានចូលរួមក្នុងការបង្ហាញពីការធ្វើសួនបន្លែនោះ ។ ជាលទ្ធផលគ្រួសារចំនួន១៦ បានបង្កើតសួនបន្លែនៅផ្ទះរបស់ពួកគេដោយជោគជ័យ (ដែលគោលដៅពីដំបូងមានចំនួនត្រឹមតែ១០គ្រួសារ) ។ នេះគឺពិតជាភាពជោគជ័យមួយដ៏អស្ចារ្យ រហូតដល់គ្រួសារចំនួនដប់មួយ អាចលក់បន្លែដែលគេដាំលើស ទៅអោយអ្នកក្នុងសហគមន៍ ហើយបានបង្កើនសេដ្ឋកិច្ចគ្រួសាររបស់ពួកគេ ក៏ដូចជាជួយអោយគ្រួសារដែលមិនមានសួនបន្លែនៅផ្ទះរបស់ពួកគេអាចទទួលបាននូវអាហាររូបត្ថម្ភផងដែរ ។

សួនបន្លែនៅតាមផ្ទះរបស់គ្រួសារជាច្រើន បានបង្កើនជំនាញកសិកម្ម និងបទពិសោធន៍ ក៏ដូចជាបានបង្កើនអាហាររូបត្ថម្ភដល់សមាជិករបស់ពួកគេ ។ លើសពីនេះទៅទៀត សួនបន្លែទាំងនោះក៏បានដើរតួនាទីជាឧបករណ៍សិក្សាសំរាប់ប្រជាជនដទៃទៀតក្នុងសហគមន៍ ។ បច្ចេកទេសដែលត្រូវបានណែនាំនៅក្នុងវគ្គបណ្តុះបណ្តាល មានលក្ខណៈថ្មីចំពោះកសិករ និងអ្នកចូលចិត្តដាំជំណាំភាគច្រើននៅទីនោះ ការលេចលឺអំពីចំណេះដឹងថ្មី ព្រមទាំងការណ៍ដែលដៃគូការងារ និងគ្រួសារជាច្រើនដើរតួនាទីជាគំរូ និងជាគ្រូបង្រៀនផងនោះ បានបង្កើនសមត្ថភាពដល់អ្នកនៅក្នុងសហគមន៍តាមរយៈការបង្កើនបន្លែដែលពួកគេអាចរកបានក្នុងសហគមន៍ ព្រមទាំងពលករជំនាញប្រសើរជាងមុន ។ ក្នុងរយៈពេលវែង គំរោងនេះនឹងនាំអោយប្រជាជនក្នុងសហគមន៍មានសុខភាពល្អប្រសើរជាងមុន មានសិស្សានុសិស្សចូលរៀនច្រើនជាងមុន និងប្រជាជនមានជីវភាពប្រសើរជាងមុន។

## ពីការបោះជំរុំទៅដល់ថ្នាក់រៀន៖ ការរីករាលដាលនៃការផ្ដល់អំណាច

ដោយអ្នកស្ម័គ្រចិត្ត៖ ***Roger Armendariz***


សិស្សប្រុស និងសិស្សស្រីចូលរួមការបោះជំរុំ *HOPE*

នៅក្នុង សាលារៀនរបស់ខ្ញុំ សិស្សភាគច្រើនគឺជាសិស្សស្រី ។ ទោះបី ជា យ៉ាងណាក៏ដោយន្ទាប់ពីបានបង្រៀននៅក្នុងសហគមន៍របស់ខ្ញុំ ខ្ញុំបានរកឃើញថាសិស្សប្រុសមានភាពក្លាហានក្នុងការឆ្លើយសំនួរទោះបីជាសិស្សស្រីនៅក្នុងថ្នាក់ដឹងចំលើយក៏ដោយ ។ ជាទូទៅ ខ្ញុំសង្កេតឃើញសិស្សស្រីរបស់ខ្ញុំជាច្រើននៅស្ងៀមស្ងាត់ ហើយមិនសូវមានទំនុកចិត្តក្នុងជំនាញសិក្សារបស់ពួកគេទេ ទោះបីជាពួកគេ ធ្វើបានពិន្ទុល្អជារួមសឹងតែនៅគ្រប់ការប្រលងទាំងអស់ក៏ដោយ ។ រឿងនេះបានបង្ហាញកាន់តែច្បាស់ទៀតនៅពេលដែលត្រូវជ្រើសរើសសិស្សដើម្បីចូលរួមក្នុងការបោះជំរុំ HOPE ។ មានសិស្សប្រុសជាច្រើនដែលបានចុះឈ្មោះ ហើយមានសិស្សស្រីតែពីរឬបីនាក់ប៉ុណ្ណោះ ។

នៅក្នុងការបោះជំរុំ HOPE យើងបានអញ្ជើញវាគ្មិនមួយចំនួនមកនិយាយ ។ វាគ្មិនម្នាក់ក្នុងចំណោមនោះមកពីមជ្ឈមណ្ឌលធនធានស្ត្រី ។ នៅចុងបញ្ចប់នៃការបោះជំរុំ សិស្សទាំងអស់ត្រូវគ្រោងរៀបចំការធ្វើបទបង្ហាញដល់សាលារៀននៅក្នុងភូមិរបស់យើង ។ ដោយមានការជួយពីខ្ញុំ ពួកគេបានគ្រោងពេលល្ងាចមួយ ដែលសិស្សទាំងអស់ត្រូវទទួលបានពត៌មានពីមជ្ឈមណ្ឌលធនធានស្ត្រី ដែលត្រូវធ្វើបទបង្ហាញដោយសិស្សដែលបានចូលរួមក្នុងការបោះជំរុំ HOPE ។ សិស្សរបស់ខ្ញុំជាង២៥នាក់ បានចូលរួមក្នុងកម្មវិធីនោះ ។

បន្ទាប់មកខ្ញុំបានសង្កេតឃើញការប្រែប្រួលជាបន្តបន្ទាប់ ដែលសិស្សស្រីដែលបាន ចូ លរួមក្នុងការបោះជំរុំ បានប្រែប្រួលទៅជាហ៊ាននិយាយច្រើនជាងមុននៅក្នុងថ្នាក់ ។ ជាលទ្ធផល សិស្សស្រីផ្សេងៗទៀតនៅក្នុងថ្នាក់រៀនក៏បានចាប់ផ្ដើមបង្ហាញពីការចាប់ផ្ដើមរបស់ពួកគេ ។ នៅពេលដែលខ្ញុំបានសង្កេតឃើញការប្រែប្រួលនេះ ខ្ញុំបានធ្វើអោយប្រាកដថាខ្ញុំនិងគ្រូដៃគូរបស់ខ្ញុំលើកទឹកចិត្តអោយសិស្សទាំងអស់ធ្វើដូចនោះនៅក្នុងថ្នាក់រៀន ។ រឿងនេះក៏បានជះឥទ្ធិពលដល់គំនិតរបស់ខ្ញុំក្នុងការធ្វើគំរោងផងដែរ ដោយសារវាគឺជាកំលាំងជំរុញអោយខ្ញុំបញ្ចូលការផ្ដល់អំណាចនិងកន្លែងមួយដែលអាចនាំអោយមានភាពជាអ្នកដឹកនាំនៅក្នុងគំរោងរបស់ខ្ញុំ ។ ទោះបីជាការប្រែប្រួលរបស់សិស្សស្រីបានចាប់ផ្ដើមមានប្រសិទ្ធិភាពហើយក៏ដោយ ក៏ខ្ញុំនិងគ្រូដៃគូរបស់ខ្ញុំសង្ឃឹមថានឹងលើកកំពស់គំនិតផ្ដួចផ្ដើមក្នុងចំណោមសិស្សស្រីផងដែរ ។

## ការបោះជំរុំ Camp BUILD៖ អ្នកដឹកនាំសម្រាប់ថ្ងៃអនាគត

ដោយអ្នកស្ម័គ្រចិត្ត៖ ***Thomas Estruth***


សិស្សប្រុសចូលរួមការបោះជំរុំ BUILD

ពីរ ថ្ងៃ បន្ទាប់ពី បា នត្រលប់មកដល់ផ្ទះវិញពីការបោះជំរុំCampBUILD ពៅ និង ភ័ក្រ្ត ដែលជាសិស្សថ្នាក់ទី១០D ទាំងពីរនាក់នៅវិទ្យាល័យកំពង់ នរស្នួរគ្រូរបស់ពួកគេថាតើពួកគេអា ចរៀ បរាប់អំពីថ្ងៃចុងសប្ដាហ៍ របស់ពួកគេដល់មិត្តភក្តិក្នុងថ្នាក់របស់ពួកគេបានឬទេ ។ ពៅ និងភ័ ក្រ្ត បានរៀបរាប់អំពីការបោះ ជំរុំ Camp BUILD ជាលំអិតអំពីអ្វីដែលពួកគេបានរៀនពីអង្គការ បរិ ស្ថា នមួយដែលបានធ្វើបទបង្ហាញ បង្ហាញពីរបៀបបិទបង់រុំ បួស ល្ងើ កដៃគ្រេចប្រាប់មិត្តរួមថ្នាក់របស់គេអំពីឱកាសអាហាររូបករណ៍ជាច្រើ ន ដែលមាន នៅសកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា ក៏ ដូចជានៅក្រៅប្រទេស ហើយជាចុងក្រោយពួកគេបាននិយាយអំពីពេលវេលាសប្បាយៗ ដែលពួកគេបានចូល រួមក្នុងពិធីជប់លៀងរាំកំសាន្តនាពេលយប់ថ្ងៃសៅរ៍ជាមួយនឹងមិត្តភ័ក្តិថ្មីៗរបស់ពួកគេដែលមកពី កន្លែងផ្សេងៗ ។ សិស្សទាំងពីរនាក់នោះបាននិយាយអស់រយៈពេល៣០នាទី ហើយនៅចុងបញ្ចប់មិត្តរួមថ្នាក់ របស់ពួកគេបានសុំពួក គេ ទៅចូលរួមការបោះជំរុំ Camp BUILD ឬ Camp GLOW នៅឆ្នាំក្រោយដែរ ។

ការបោះជំរុំ C amp BUILD (ដែលមានន័យថា ក្មេងប្រុសរួមគ្នាក្នុងការអភិវឌ្ឍភាពជាអ្នកដឹកនាំ) គឺជាការបោះជំរុំសំរាប់តែក្មេងប្រុសដែលផ្ដោតលើសុ ខភាព ការរៀបចំផែនការការងារ ការត្រៀមខ្លួនចូលមហាវិទ្យាល័យ អំពើហិង្សាក្នុងគ្រួសារ ទំនាក់ទំនងល្អ ស្មារតីក្នុងការស្ម័គ្រចិត្ត និងការការពារនិងថែរក្សាបរិស្ថាន ។ ក្មេងប្រុសដែលបានចូលរួមក្នុងការបោះជំរុំនេះមានអាយុពី១៥ដល់២៥ឆ្នាំដែលជាវ័យមួយដ៏សំខាន់ ។ មួយភាគធំនៃពួកគេនឹងត្រូវរៀបការក្នុងកំឡុងពេលពីរទៅបីឆ្នាំខាងមុខ ហើយចាប់ផ្ដើមគ្រួសារព្រមទាំងចាប់ផ្ដើមមុខរបរផ្សេងៗ ។ ការបោះជំរុំ Camp BUILD ជួយគាំទ្រក្មេងប្រុសទាំងអស់អោយមានការអភិវឌ្ឍបំណិតជីវិតសំខាន់ៗ សមត្ថភាពលើភាពជា អ្នកដឹកនាំ និងការគោរពស្ត្រី ដែលនឹងត្រូវប្រើប្រាស់នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ក៏ដូចជាចែករំលែកជាមួយ ប្រជាជនក្នុងសហគមន៍របស់ពួកគេផងដែរ ។

ការបោះជំរុំ Camp BUILD បាននាំក្មេងប្រុសទាំងអស់៧៣នាក់ពីខេត្តកំពត និងខេត្តកំពង់ស្ពឺអោយចូលរួមក្នុងសិក្ខាសាលារយៈពេលបីថ្ងៃ ។ បន្ទាប់ពីបានចូលរួមក្នុងការបោះជំរុំនេះហើយ អ្នកចូលរួមទាំងអស់បានត្រលប់ទៅក្នុងសហគមន៍របស់ពួកគេវិញ និងចែករំលែកជាមួយមិត្តភក្តិនិងក្រុមគ្រួសាររបស់ពួកគេអំពីអ្វីដែលពួកគេបានរៀន ។ ក្រុមក្មេងប្រុសមួយក្រុមបានដឹកនាំការធ្វើការវាយតំលៃពីតំរូវការជាមួយសហគមន៍របស់ពួកគេ បានកំណត់គោលដៅ សរសេរកម្មវត្ថុ និងបានបង្កើតគំរោងមួយដើម្បីបង្កើតបណ្ណាល័យសហគមន៍ ។ សារៈសំខាន់នៃការបោះជំរុំ Camp BUILD បានផ្ដល់ផលប្រយោជន៍ដោយផ្ទាល់ដល់ក្មេងប្រុសចំនួន៧៣នាក់ដែលបានចូលរួម និងដោយមិនផ្ទាល់ដល់ប្រជាជនក្នុងសហគមន៍ជាង៧០០នាក់ ។

ភីសខ័រ គឺជាស្ថាប័នដែលមិនប្រកាន់និន្នាការនយោបាយ និង សាសនា របស់រដ្ឋាភិបាល សហរដ្ឋអាមេរិក ដែលធ្វើការដើម្បីលើកកំពស់សន្តិភាព និង មិត្តភាពរវាងប្រជាជននៃប្រទេស និងវប្បធម៌ផ្សេងៗគ្នា ។ អស់រយៈពេលជាងប្រាំទសវត្សកន្លងទៅនេះ ភ្នាក់ងារ ភីសខ័របានផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសចំនួន១៣៩ តាមរយៈការអនុវត្តគំរោងក្នុងវិស័យអប់រំ ការអភិវឌ្ឍអាជីវកម្ម ការការពារបរិស្ថាន កសិកម្ម និងសុខភាព ។




**ពត៌មានទំនាក់ទំនង៖**

ភ្នាក់ងារ ភីសខ័រប្រចាំនៅកម្ពុជា
ប្រអប់សំបុត្រលេខ ២៤៥៣ ភ្នំពេញ ៣ ព្រះរាជាណាចក្រកម្ពុជា
ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

ទូរស័ព្ទលេខ៖ +៨៥៥ ២៣ ២២២ ៩០១
ទូរសារលេខ៖ +៨៥៥ ២៣ ២២២ ៩០៣

អ៊ីមែល៖ info@kh.peacecorps.gov
គេហទំព័រ៖ http://cambodia.peacecorps.gov

**ស្វែងរកយើងតាម៖**

cambodia.peacecorps
peacecorpscambodia


ខែមករា ឆ្នាំ២០១៦